**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អង្គភាពអនុវត្តគម្រោងពិពិធកម្មកសិកម្មកម្ពុជា**

# របាយការណ៍កិច្ចប្រជុំ

# គណៈកម្មការវាយតម្លៃ នៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា

## ១. កម្មវត្ថុនៃកិច្ចប្រជុំ

នៅថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០២១, គណៈកម្មការវាយតម្លៃ (Evaluation Committee-EC) នៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា (Cambodia Agricultural Sector Diversification Project-CASDP) បានបើកកិច្ចប្រជុំពិនិត្យ, វាយតម្លៃ និងដាក់ពិន្ទុលើសំណើពិពិធកម្មនិងធុរកិច្ចរបស់ “**សហគមន៍កសិកម្មសាមគ្គីភ្នំពេជ្របុរី** (DPr ២៥)” និង “**សហគមន៍កសិកម្មស្ត្រីរតនៈ** (DPr ២៦)” មុននឹងបញ្ជូនបន្តទៅកាន់គណៈកម្មការប្រឹក្សាយោបល់និងអនុម័ត (Advisory and Endorsement Committee-AEC) ដើម្បីពិនិត្យ និងអនុម័តជាផ្លូវការ ដើម្បីអនុញ្ញាតឱ្យសហគមន៍កសិកម្មរៀបចំផែនការពិពិធកម្មនិងធុរកិច្ចបន្តទៀត។

## ២. សមាសភាពអង្គប្រជុំ

កិច្ចប្រជុំត្រូវបានដឹកនាំដោយ **លោក ឡៅ ប៉ូលីវេត** អនុប្រធាននាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ និងជាប្រធានគណៈកម្មការវាយតម្លៃ (EC) ដោយមានការចូលរួមពីសមាជិក និងសមាជិកា នៃគណៈកម្មការចំនួន ០៧ រូប រួមមាន÷ ១. លោក **ហុក គឹមធួន**, ២. លោក **ឆេង វិបុលរិទ្ធ**, ៣. លោក **ទិត្យ សុផា**, ៤. លោក **ហែម វិសាល** (តំណាងឱ្យលោក **សុខ បូរ៉ែន**), ៥. លោកស្រី **ជា សុខអ៊ីម** និង ៦. លោកស្រី **ហ៊ឹង លីហួង** (តំណាងឱ្យលោក សុខ រឿន)។ ចំណែកឯលោក **ដុក លួន** បានអវត្តមានក្នុងកិច្ចប្រជុំនេះ ដោយមានធុរៈ។

## ៣. សេចក្តីសង្ខេបពីសំណើពិពិធកម្ម និងធុរកិច្ច

១. **សហគមន៍កសិកម្មសាមគ្គីភ្នំពេជ្របុរី** មានទីតាំងស្ថិតនៅភូមិស្របាល ឃុំភ្នំពេញ ស្រុកគូលែន ខេត្តព្រះវិហារ បានចូលរួមដាក់សំណើពិពិធកម្មនិងធុរកិច្ច (ការពង្រឹងពង្រីកទីផ្សារដំឡូងមី) ដែលមានសមាជិកទទួលផលសរុប ៣៥២ នាក់ ក្នុងនោះមានស្ត្រី ១៨៦ នាក់ (ដោយបែងចែកសមាជិកផលិតករជា ០៨ ក្រុមផលិត មកពីភូមិព្នៅ ភូមិបុស្ស និងភូមិស្របាល ឃុំភ្នំពេញ ស្រុកគូលែន ខេត្តព្រះវិហារ)។ សហគមន៍បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការ ដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង

នេសាទ ខេត្តព្រះវិហារ តាមរយៈលិខិតចុះបញ្ជីលេខ ០២២ ម.កសក.ពហ ដែលមានវិញ្ញាបនបត្រលេខ ០២៤ ម.កសក. ពហ/ស.ក.ក ចុះថ្ងៃទី ២៤ សីហា ឆ្នាំ ២០១៤។ សហគមន៍មានមុខរបរចម្បងៗដែលកំពុងដំណើរការសព្វថ្ងៃ ដូចជា÷ ឥណទានសាច់ប្រាក់ ប្រាក់សន្សំ លក់ស្រូវសរីរាង្គ លក់ដំឡូងមីសរីរាង្គ លក់ដំឡូងមីស្ងួត លក់ទឹកស្អាត (២ ភូមិ) លក់ទឹកសូឡា លក់ជីសរីរាង្គខ្ចប សេវាកម្មជួលម៉ាស៊ីនច្រូតស្រូវ កិនអង្ករលក់ និងលក់ស្រូវពូជ។

ក្រោយពីទទួលបានព័ត៌មានពីគម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP), សហគមន៍កសិកម្មសាមគ្គីភ្នំពេជ្របុរី បានរៀបចំសំណើពិពិធកម្មនិងធុរកិច្ចដែលមានតម្រូវការទឹកប្រាក់សរុបចំនួន **៦០៣ ៩៦៣,២០** ដុល្លារអាមេរិក ដោយផ្តោតលើ **"ការពង្រឹងពង្រីកទីផ្សារដំឡូងមី"** ដើម្បីដាក់ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធធ្វើការពិនិត្យពិចារណា និងគាំទ្រហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ។

គោលដៅរួមនៃសំណើពិពិធកម្មនិងធុរកិច្ចរបស់សហគមន៍កសិកម្មសាមគ្គីភ្នំពេជ្របុរី គឺ ÷

- ពង្រីកទីផ្សារ**ដំឡូងសរីរាង្គស្រស់** ក្នុងឆ្នាំ ២០២២ ឱ្យបានលើសពី ៨ ៤៩៨ តោន ដែលទទួលចំណូលបានប្រមាណ ៧៦៤ ៨២០ ដុល្លារអាមេរិក, ក្នុងឆ្នាំ ២០២៣ ចំនួន ៨ ៩៣៧ តោន ដែលទទួលបានចំណូលប្រមាណ ៨០៤ ៣៣០ ដុល្លារអាមេរិក និងក្នុងឆ្នាំ ២០២៤ ប្រមាណ ៩ ៤៣៧ តោន ដែលទទួលចំណូលប្រមាណ ៨៤៩ ៣៣០ ដុល្លារអាមេរិក និងបូកតម្លៃបន្ថែម ២០% ក្នុងមួយគីឡូក្រាម។
- ពង្រីកទីផ្សារ**ដំឡូងមីស្ងួត** ក្នុងឆ្នាំ ២០២២ ឱ្យបានលើសពី ៣ ៨០៧ តោន ដែលទទួលចំណូលបាន ៧៦១ ៤០០ ដុល្លារអាមេរិក, ក្នុងឆ្នាំ ២០២៣ ចំនួន ៤ ៣០៧ តោន ដែលទទួលបានចំណូលប្រមាណ ៨៦១ ៤០០ ដុល្លារអាមេរិក និងក្នុងឆ្នាំ ២០២៤ រហូតដល់ ៤ ៨០៧ តោន ដែលទទួលចំណូលប្រមាណ ៩៦១ ៤០០ ដុល្លារអាមេរិក និងបូកតម្លៃបន្ថែម ២០% ក្នុងមួយគីឡូក្រាម។
- សេវាកម្មដឹកដំឡូងមី ក្នុងឆ្នាំ ២០២២ ឱ្យបានលើសពី ១២ ៣០៥ តោន ដែលទទួលបានចំណូល ១១០ ០៣២ ដុល្លារអាមេរិក, ក្នុងឆ្នាំ ២០២៣ ចំនួន ១៣ ២៤៤ តោន ទទួលចំណូលបាន ១៦៥ ៥៥០ ដុល្លារអាមេរិក និងក្នុងឆ្នាំ ២០២៤ ចំនួន ១៤ ២៤៤ តោន ទទួលបានចំណូល ១៧៨ ០៥០ ដុល្លារអាមេរិក។

ក្នុងនោះ មានប្រភពថវិកាដូចខាងក្រោម÷

**<u>ថវិកាសម្រាប់សហគមន៍</u>**

- ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពីគម្រោង CASDP សរុប ៣០ ៦៩៦ ដុល្លារអាមេរិក
- កម្ចីពីគ្រឹះស្ថានហិរញ្ញវត្ថុក្រៅគម្រោង សរុប ១៨២ ៤០៥ ដុល្លារអាមេរិក
- ទុនបដិភាគពីសហគមន៍ សរុប ៧១ ០៩៩ ដុល្លារអាមេរិក

ដូច្នេះ ថវិកាវិនិយោគរបស់សហគមន៍ គ្រោងទឹកប្រាក់សរុបចំនួន ២៨៤ ២០០ ដុល្លារអាមេរិក។

**<u>ថវិកាសម្រាប់ក្រុមផលិត</u>**

- ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពីគម្រោង CASDP សរុប ៥៣ ៦៤៩,២០ ដុល្លារអាមេរិក

- កម្ចីពីគ្រឹះស្ថានហិរញ្ញវត្ថុក្រៅគម្រោង សរុប ៨៨ ៥០០ ដុល្លារអាមេរិក
- ទុនបដិភាគពីក្រុមផលិត សរុប ១៧៧ ៦១៤ ដុល្លារអាមេរិក

ដូច្នេះ ថវិកាវិនិយោគរបស់ក្រុមផលិត គ្រោងទឹកប្រាក់សរុបចំនួន ៣១៩ ៧៦៣,២០ ដុល្លារអាមេរិក។

**២. សហគមន៍កសិកម្មស្ត្រីរតនៈ** មានទីតាំងស្ថិតនៅភូមិស្អាង ឃុំស្អាង ស្រុកជ័យសែន ខេត្តព្រះវិហារ បានចូលរួមដាក់សំណើពិពិធកម្មនិងធុរកិច្ច (ការពង្រឹងពង្រីកទីផ្សារដំឡូងមី) ដែលមានសមាជិកទទួលផលសរុប ២៣៣ នាក់ ក្នុងនោះមានស្ត្រី ១៧៦ នាក់ (ដោយបែងចែកសមាជិកជាផលិតករដំឡូងមីស្រស់ជា ៨ ក្រុម និងសមាជិកជាផលិតករដំឡូងស្ងួតជា ១០ ក្រុម មកពីភូមិម៉ឺនរាជ ស្អាង ខ្យង សំរោង គោគ ស្លែង និងភូមិតស៊ូ) ស្ថិតក្នុងឃុំស្អាង ខ្យង និងតស៊ូ ស្រុកជ័យសែន ខេត្តព្រះវិហារ ។ សហគមន៍ បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះវិហារ តាមរយៈលិខិតចុះបញ្ជីលេខ ០១៤ ម.កសក.ពហ ដែលមានវិញ្ញាបនបត្រលេខ ០០៣ ម.កសក.ពហ/ស.ក.ក ចុះថ្ងៃទី ០៥ ខុសភា ឆ្នាំ ២០១០។ សហគមន៍កសិកម្មមានមុខរបរចម្បងៗ ដែលកំពុងដំណើរការសព្វថ្ងៃ ដូចជា÷ លក់មើមដំឡូងស្រស់-ស្ងួត ផលិតទឹកសុទ្ធលក់ លក់ស្រូវសរីរាង្គ លក់ជីសរីរាង្គខ្ចប ឥណទានសាច់ប្រាក់ឱ្យសមាជិក និងដាំបន្លែ។

ក្រោយពីទទួលបានព័ត៌មានពីគម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP), សហគមន៍កសិកម្មស្ត្រីរតនៈ បានរៀបចំសំណើពិពិធកម្មនិងធុរកិច្ច ដែលមានតម្រូវការទឹកប្រាក់សរុបចំនួន ២៩៣ ២៣៥,៤០ ដុល្លារអាមេរិក ដោយផ្តោតលើ **"ការពង្រឹងពង្រីកទីផ្សារដំឡូងមី"** ដើម្បីដាក់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធធ្វើការពិនិត្យ ពិចារណា និងគាំទ្រហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ។

គោលដៅរួមនៃសំណើពិពិធកម្មនិងធុរកិច្ចរបស់សហគមន៍កសិកម្មស្ត្រីរតនៈ គឺ ÷

- ពង្រីកទីផ្សារ**ដំឡូងសរីរាង្គស្រស់** ក្នុងឆ្នាំ ២០២២ ឱ្យបានលើសពី ៤ ៤៣៥ តោន ដែលទទួលចំណូលប្រមាណ ៣៩៩ ១៥០ ដុល្លារអាមេរិក, ក្នុងឆ្នាំ ២០២៣ ចំនួន ៤ ៩៣៥ តោន ដែលទទួលបានចំណូលប្រមាណ ៤៤៤ ១៥០ ដុល្លារអាមេរិក និងក្នុងឆ្នាំ ២០២៤ ចំនួន ៥ ៤៣៥ តោន ដែលទទួលចំណូលប្រមាណ ៤៨៩ ១៥០ ដុល្លារអាមេរិក និងបូកតម្លៃបន្ថែម ២០% ក្នុងគីឡូក្រាម។
- ពង្រីកទីផ្សារ**ដំឡូងមីស្ងួត** ក្នុងឆ្នាំ ២០២២ ឱ្យបាន ៦ ៨២០ តោន ដែលទទួលបានចំណូលប្រមាណ ១ ៣៦៤ ០០០ ដុល្លារអាមេរិក, ក្នុងឆ្នាំ ២០២៣ ចំនួន ៧ ៣២០តោន ដែលទទួលបានចំណូលប្រមាណ ១ ៤៦៤ ០០០ដុល្លារអាមេរិក និងក្នុងឆ្នាំ២០២៤ ចំនួន ៧ ៨២០ តោន ដែលទទួលបានចំណូលប្រមាណ ១ ៥៦៤ ០០០ដុល្លារអាមេរិក និងបូកតម្លៃបន្ថែម ២០% ក្នុងគីឡូក្រាម។

ក្នុងនោះ មានប្រភពថវិកាដូចខាងក្រោម÷

**ថវិកាសម្រាប់សហគមន៍**

- ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពីគម្រោង CASDP សរុប ៨ ៨០០ ដុល្លារអាមេរិក
- កម្ចីពីគ្រឹះស្ថានហិរញ្ញវត្ថុក្រៅគម្រោង សរុប ៩៥ ០០០ ដុល្លារអាមេរិក
- ទុនបដិភាគពីសហគមន៍ សរុប ៦៥ ៧៩០ ដុល្លារអាមេរិក

ដូច្នេះ ថវិកាវិនិយោគរបស់សហគមន៍ គ្រោងទឹកប្រាក់សរុបចំនួន ១៦៩ ៥៩០ ដុល្លារអាមេរិក។

**<u>ថវិកាសម្រាប់ក្រុមផលិត</u>**

- ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពីគម្រោង CASDP សរុប ១៦ ៥៣៧,៤០ ដុល្លារអាមេរិក
- កម្ចីពីគ្រឹះស្ថានហិរញ្ញវត្ថុក្រៅគម្រោង សរុប ៣៨ ០០០ ដុល្លារអាមេរិក
- ទុនបដិភាគពីសមាជិកក្រុមផលិត សរុប ៦៩ ១០៨ ដុល្លារអាមេរិក

ដូច្នេះ ថវិកាវិនិយោគរបស់ក្រុមផលិត គ្រោងទឹកប្រាក់សរុបចំនួន ១២៣ ៦៤៥,៤០ ដុល្លារអាមេរិក។

## ៤. នីតិវិធីនៃការវាយតម្លៃ និងដាក់ពិន្ទុ លើសំណើពិពិធកម្ម

ការដាក់ពិន្ទុលើសំណើពិពិធកម្មនិងធុរកិច្ច (DPr) ត្រូវបានធ្វើឡើងដោយសមាជិកគណៈកម្មការ EC ម្នាក់ៗ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យជាគោលចំនួន ៧ ចំណុច រួមមាន÷ ១) ភាពពាក់ព័ន្ធរបស់ DPr ជាមួយក្របខ័ណ្ឌគម្រោង, ២) បទពិសោធន៍របស់តួអង្គពាក់ព័ន្ធក្នុងការប្រកបអាជីវកម្ម, ៣) ការរៀបចំ DPr/BPr, ៤) ឧបសគ្គ និងហានិភ័យដែលនឹងត្រូវធ្វើការឆ្លើយតប, ៥) ការវិភាគហិរញ្ញវត្ថុ, ៦) ផលជះផ្នែកបរិស្ថាន និង ៧) ផលជះផ្នែកសង្គមរបស់គម្រោង។ សមាជិកម្នាក់ធ្វើការដាក់ពិន្ទុលើសំណើ ចន្លោះពី ១ ទៅ ១០០ ពិន្ទុ លើសំណើពិពិធកម្មនិងធុរកិច្ច ម្តងមួយៗ។ ទន្ទឹមនេះ ពិន្ទុដែលផ្តល់ដោយសមាជិកម្នាក់ៗរបស់គណៈកម្មការវាយតម្លៃ មិនត្រូវបានអនុញ្ញាតឱ្យចែករំលែកដល់សមាជិកដទៃទៀតដឹងនោះឡើយ។ សំណើពិពិធកម្មនិងធុរកិច្ចមួយដែលត្រូវបានវាយតម្លៃដោយសមាជិកគណៈកម្មការ EC ចំនួន ៨ រូប គឺអាចមានពិន្ទុអតិបរមាត្រឹម ៨០០ ពិន្ទុ។

## ៥. លទ្ធផលនៃការវាយតម្លៃ និងដាក់ពិន្ទុ

តាមរយៈការធ្វើមធ្យមភាគ នៃពិន្ទុទាំងអស់របស់សមាជិកគណៈកម្មការ EC លើសំណើពិពិធកម្មនិងធុរកិច្ចរបស់សហគមន៍កសិកម្មទាំងពីរខាងលើនេះ បានបង្ហាញឱ្យឃើញថា **“សហគមន៍កសិកម្មសាមគ្គីភ្នំពេជ្របុរី”** ទទួលបានពិន្ទុចំនួន **៧២,៨០** លើពិន្ទុសរុប ១០០ ចំណែកឯ **“សហគមន៍កសិកម្មស្ត្រីរតនះ”** ទទួលបានពិន្ទុចំនួន **៧២,០០** លើពិន្ទុសរុប ១០០ ។

ការវាយតម្លៃតាមលក្ខណៈវិនិច្ឆ័យរបស់សមាជិកគណៈកម្មការ EC ម្នាក់ៗ មានខ្លឹមសារលម្អិតក្នុងតារាងខាងក្រោម÷

# គណៈកម្មការវាយតម្លៃ "សំណើពិពិធកម្មនិងធុរកិច្ចរបស់ សហគមន៍កសិកម្មសាមគ្គីត្នំពេជ្របុរី "

| ល.រ | ចំណុចត្រូវវាយតម្លៃ | ពិន្ទុអតិបរមា | ពិន្ទុផ្តល់ដោយសមាជិក | | | | | | | | | សេចក្តីពន្យល់ពីការដាក់ពិន្ទុ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | EC1 | EC2 | EC3 | EC4 | EC5 | EC6 | EC7 | EC8 | Average Score | |
| **១. ភាពពាក់ព័ន្ធនៃDPI ជាមួយក្របខ័ណ្ឌគម្រោង** | | | | | | | | | | | | |
| | ១.១. សនិទានភាព (ហេតុផល) និងគោលដៅ DPI គឺរៀបចំសរសេរបានល្អ<br>The rationale and objectives of the proposed DPI are well formulated | 5 | 3 | 4 | 4 | 4 | 4 | 4 | 4 | 4 | 3.9 | គួរឱ្យចាប់អារម្មណ៍ខ្លាំង (impressive) = ៥;<br>ល្អប្រសើរ (substantially)= ៤<br>ល្អ (good) = ៣;<br>ខ្លះៗ (Some) = ២,<br>ខ្សោយ (poor) = ១ |
| | ១.២. ភាពពាក់ព័ន្ធរបស់DPI នេះ នឹងជួយឱ្យសម្រេចគោលដៅគម្រោងCASDP<br>The relevance of the proposed DPI to reach the objective of the CASDP project | 5 | 3 | 3 | 4 | 4 | 4 | 3 | 4 | 4 | 3.6 | គួរឱ្យចាប់អារម្មណ៍ខ្លាំង (impressive) = ៥;<br>ល្អប្រសើរ (substantially) = ៤;<br>ល្អ (good) = ៣;<br>ខ្លះៗ (some) = ២,<br>ខ្សោយ (poor) = ១ |
| **២. បទពិសោធន៍របស់តួអង្គពាក់ព័ន្ធ** | | | | | | | | | | | | |
| | ២.១. ចំនួនឆ្នាំគិតជាមធ្យមនៃការប្រកបអាជីវកម្មរបស់ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូច និងមធ្យម ដែលបានចុះបញ្ជី<br>Average year of legal constitution of POs and SMAs | 5 | 4 | 3 | 4 | 4 | 4 | 3 | 4 | 3 | 3.6 | លើសពី ៣ ឆ្នាំ = ៥;<br>ចន្លោះពី ២ ទៅ ៣ ឆ្នាំ = ៤;<br>ចន្លោះពី ១ ទៅ ២ ឆ្នាំ = ៣;<br>ចន្លោះពី 0,៥ ទៅ ១ ឆ្នាំ =២;<br>តិចជាង 0,៥ ឆ្នាំ = ១ |
| | ២.២. បទពិសោធន៍របស់ក្រុមផលិត ក្នុងការលក់ផលិតរបស់ខ្លួនរួមគ្នាជាក្រុម<br>Experience of PO to market their products together as a group | 5 | 3 | 3 | 4 | 4 | 3 | 4 | 4 | 3 | 3.5 | គួរឱ្យចាប់អារម្មណ៍ខ្លាំង = ៥;<br>ល្អប្រសើរ = ៤;<br>ល្អ = ៣;<br>ខ្លះៗ = ២,<br>ខ្សោយ = ១ |
| | ២.៣. BPI នីមួយៗ របស់ DPI មានភ្ជាប់មកជាមួយនូវ លិខិតបញ្ជាក់បំណងក្នុងការ ទិញទំនិញពីដៃគូអ្នកបញ្ជា ទិញ<br>Each BPI of the DPI is supported by a letter of intent of purchase by a potential buyer. | 5 | 3 | 4 | 3 | 4 | 3 | 3 | 4 | 4 | 3.5 | DPI មានលិខិតបញ្ជាក់បំណង ១០០% = ៥;<br>DPI មានលិខិតបញ្ជាក់បំណងលើសពី៥០% = ៤<br>DPI មានលិខិតបញ្ជាក់បំណង ៥០%=៣<br>DPI មានលិខិតបញ្ជាក់បំណងតិចជាង ៥០%=២<br>DPI ពុំមានលិខិតបញ្ជាក់បំណង ០%=១ |
| **៣. ការរៀបចំDPI/ BPI** | | | | | | | | | | | | |
| | ៣.១. ការជ្រើសរើសការ វិនិយោគដែលមានផលិតភាពនៅក្នុង BPI របស់ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូច និងមធ្យមគឺត្រឹមត្រូវ និងសម ស្រប ដែលនឹងអាចសម្រេច បានទៅតាមគោលដៅ របស់ DPI និង BPI ហើយនិងគោលដៅអភិវឌ្ឍន៍របស់គម្រោង<br>(Productive investment in BPI for POs and SMAs are well chosen to achieve the objective of the DPI and BPI and the development objective of the Project.) | 10 | 8 | 6 | 8 | 8 | 8 | 6 | 6 | 8 | 7.3 | ទាំងស្រុង (Totally) = ១០;<br>បង្គួរ (substantially) = ៨;<br>ភាគច្រើន (mostly) = ៦;<br>ល្មមគ្រប់គ្រាន់ (just enough) = ៤;<br>មិនគ្រប់គ្រាន់ (not enough) = ២ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ៣.២. ផែនការ BPI នៅក្នុង DPI គឺមានដាក់បញ្ចូលនូវ ដំណើរការ ក្នុងកម្រិត កសិដ្ឋាន, ប្រមូលផ្តុំ, កែច្នៃ និងទីផ្សារ ដែលមានលក្ខណៈពាណិជ្ជកម្ម ដោយប្រើប្រាស់ បច្ចេកវិទ្យា ដែលមានលក្ខណៈនវានុវត្តន៍<br>BPI in DPI include/s innovative technological and commercial processes at farm, aggregation, processing and marketing level. | 5 | 3 | 3 | 3 | 4 | 4 | 4 | 4 | 4 | 3.6 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially) = ៤;<br>ភាគច្រើន (mostly) = ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| ៣.៣. ផែនការ BPI នៅក្នុង DPI មានការដាក់បញ្ចូលនូវការបន្ថែមតម្លៃដល់ ផលិតផល កសិកម្មបឋម តាមរយៈការធ្វើ បម្លាស់ប្រែ ឬការកែច្នៃ ការជ្រើសរើស និងការធ្វើ ចំណាត់ថ្នាក់ផលិតផល តាមរយៈការវេចខ្ចប់ និងដាក់ស្លាក សម្គាល់ ជាដើម<br>BPI in DPI propose/s adding value to primary production through transformation/processing, or through product sorting and selection by physical traits and/or packing, packaging and/or labelling. | 5 | 4 | 4 | 3 | 4 | 4 | 3 | 4 | 3 | 3.6 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially)= ៤;<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough)= ២;<br>មិនគ្រប់គ្រាន់ (not enough)=១ |
| ៣.៤. ផែនការវិនិយោគលើ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ត្រូវបានជ្រើសរើស យ៉ាងត្រឹមត្រូវ ដើម្បីគាំទ្រដល់ការ សម្រេចគោលបំណង DPI និងគោលបំណង អភិវឌ្ឍន៍របស់គម្រោង ហើយថវិកា ដែលស្នើឡើងមាន លក្ខណៈ សមស្រប<br>Supporting public investments are well chosen to support achieving the objective of the DPI and the development objective of the Project, and are within acceptable budget | 5 | 3 | 4 | 3 | 4 | 4 | 4 | 3 | 3 | 3.5 | **ក. ការវាយតម្លៃដាក់ពិន្ទុប្រសិនបើសហគមន៍បានស្នើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ**<br>ទាំងស្រុង (Totally)= ៥<br>បង្គួរ (substantially)= ៤;<br>ភាគច្រើន (mostly)= ៣;<br>**ខ. ការវាយតម្លៃដាក់ពន្ទុប្រសិនបើសហគមន៍បានស្នើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ**<br>ពិន្ទុផ្តល់ឱ្យ÷ ៣ |
| ៣.៥. BPI នៅក្នុង DPI មាន អំណះអំណាងច្បាស់លាស់ដែលបញ្ជាក់ថា តម្រូវការ ទីផ្សារសម្រាប់ផលិតផល/ សេវាកម្ម ដែលបានស្នើឡើង កំពុងមានការកើនឡើង<br>The BPI under the DPI is/are supported by evidence that the targeted market for proposed products/services is growing. | 5 | 4 | 4 | 4 | 3 | 4 | 4 | 4 | 4 | 3.9 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially)= ៤;<br>ភាគច្រើន (mostly) = ៣;<br>ល្មមគ្រប់គ្រាន់ (just enough)= ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| ៣.៦. BPI នៅក្នុង DPI បានដាក់បញ្ចូលនូវការអនុវត្តកសិកម្មល្អ (GAP) និងការ អនុវត្តល្អក្នុងកម្រិតរោងចក្រ/ សហគ្រាស/ សិប្បកម្ម/ កន្លែងកែច្នៃផលិតផល កសិកម្ម (GMP)<br>BPI under DPI explicitly incorporate good agricultural practices and good manufacturing practices | 5 | 3 | 3 | 3 | 3 | 5 | 3 | 5 | 3 | 3.5 | ទាំងពីរ (Both) = ៥;<br>មួយក្នុងចំណោមទាំងពីរ (One of them) = ៣;<br>មិនមានណាមួយ (none)=១ |
| **៤. ឧបសគ្គ និងហានិភ័យ ដែលនឹងត្រូវធ្វើការឆ្លើយតប** | | | | | | | | | | | |
| តើមានការរៀបរាប់អំពីហានិភ័យ ដែលសហគមន៍/ ក្រុមផលិត/ កសិធុរកិច្ចខ្នាត តូច និងមធ្យម កំពុងជួបប្រទះនាពេលបច្ចុប្បន្ន និងវិធានការដើម្បីកាត់បន្ថយហានិភ័យទាំងនោះដែរឬទេ?<br>Are current risks and mitigation measures well formulated? | 5 | 4 | 4 | 3 | 3 | 3 | 3 | 3 | 2 | 3.1 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially) = ៤;<br>ភាគច្រើន (mostly) = ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| **៥. ការវិភាគហិរញ្ញវត្ថុ** | | | | | | | | | | |
| លទ្ធភាពទទួលបានផលចំណេញជាមធ្យមសម្រាប់ការវិនិយោគដែលបានស្នើឡើង ដោយ PO និង SMA ដែលត្រូវបានបង្ហាញជាអត្រាផលចំណេញសុទ្ធ ដែលស្មើនឹង ផលចំណេញសុទ្ធ ធៀបនឹងចំណូលពីការលក់ (Net Margin = Net Profit/ Revenues) Average financial viability for proposed investment of POs and SMAs expressed in Net Margin (= Net Profit / Revenues) | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5.0 | ជាង ១០% (More than 10%) = ៥<br>រហូតដល់ ១០% (Up to 10%) = ៣<br>រហូតដល់ ៥% (Up to 5%) = ១ |
| **៦. ផលជះផ្នែកបរិស្ថាន** | | | | | | | | | | |
| តើគម្រោងនេះផ្តល់ផលជះអ្វីខ្លះដល់បរិស្ថាន?<br>What is the impact of the project on the environment? | 5 | 4 | 5 | 3 | 4 | 4 | 3 | 4 | 4 | 3.9 | វិជ្ជមានខ្ពស់ (Very Positive) = ៥;<br>វិជ្ជមាន (Positive) = ៤;<br>វិជ្ជមានដែរ (rather positive) = ៣;<br>ធម្មតា (Neutral) = ២;<br>អវិជ្ជមាន(Negative)=១ |
| **៧. ផលជះផ្នែកសង្គមរបស់គម្រោង** | | | | | | | | | | |
| ៧.១. តើបានបញ្ជាក់ច្បាស់លាស់ពីផលជះអវិជ្ជមានផ្នែកសង្គម ចេញពីគម្រោងដែរឬទេ?<br>Are adverse social impacts identified | 5 | 3 | 5 | 3 | 3 | 3 | 3 | 5 | 3 | 3.5 | ទាំងស្រុង (Totally) =៥;<br>ភាគច្រើន (mostly)=៣;<br>មិនគ្រប់គ្រាន់ (not sufficiently) = ១ |
| ៧.២. តើ DPI នេះបានបង្កើតការងារថ្មីៗដែរឬទេ? (ការងារអចិន្ត្រៃយ៍ និងការងារតាមរដូវកាល)<br>Does the DPI create new jobs (permanent and seasonal) | 5 | 4 | 3 | 3 | 4 | 4 | 4 | 4 | 4 | 3.8 | ជាង ២០ នាក់ = ៥;<br>ចន្លោះ ១០ និង ២០ នាក់ = ៤;<br>ចន្លោះ ៥ និង ១០ នាក់ = ៣;<br>ចន្លោះ ១ និង ៥ នាក់ = ២;<br>មិនមាននរណាម្នាក់ឡើយ (none) = ១ |
| ៧.៣. តើ DPI នេះ មានផែនការជាក់លាក់ដើម្បីធានាថាស្ត្រី យុវជន និងក្រុមងាយរងគ្រោះឯទៀតនឹងទទួលបានផលប្រយោជន៍ពីគម្រោង ដែរឬទេ?<br>Does the DPI has concrete plans how to make sure that women and youth and other vulnerable groups will benefit from the Project? | 5 | 4 | 4 | 3 | 3 | 4 | 4 | 4 | 3 | 3.6 | ទាំងស្រុង (Totally)= ៥;<br>បង្គួរ(substantially)= ៤<br>ភាគច្រើន (mostly)=៣;<br>ល្មមគ្រប់គ្រាន់ (just enough)=២;<br>មិនគ្រប់គ្រាន់ (not enough)=១ |
| ៧.៤. BPI និងផែនការច្រវាក់តម្លៃ ដែលបានជ្រើសរើស មានវិយិទ្ធភាពទៅនឹងអាហារូបត្ថម្ភ (Nutrition Sensitive) ឬទេ ហើយផែនការទាំងនោះ អាចត្រូវបានកំណត់ថាជាផែនការដែលបានរួមចំណែកដល់ការកាត់បន្ថយបញ្ហានៃកង្វះអាហារូបត្ថម្ភ ក្នុងចំណោមប្រជាជនកម្ពុជាដែរឬទេ? Are the BPI and selected value chains nutrition-sensitive and can they be defined as those that can contribute to reducing undernutrition in the Cambodian population? | 5 | 3 | 2 | 3 | 2 | 3 | 3 | 3 | 3 | 2.8 | ទាំងស្រុង (Totally)= ៥;<br>បង្គួរ(substantially)= ៤<br>ភាគច្រើន (mostly)=៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) =១ |
| ៧.៥. តើ BPI និងផែនការខ្សែច្រវាក់តម្លៃផ្តោតទៅលើការនាំចេញ ហើយផែនការទាំងនោះអាចត្រូវបានកំណត់ថាជាផែនការដែលអាចរួមចំណែកដល់ការជំរុញការនាំចេញផលិតផលកសិកម្មកម្ពុជា ដែរឬទេ?<br>Are the BPI and selected value chains export-oriented and can they be defined as those that can contribute to promoting Cambodia"s exports of agricultural products? | 5 | 3 | 4 | 3 | 4 | 3 | 4 | 4 | 4 | 3.6 | ទាំងស្រុង (Totally)= ៥;<br>បង្គួរ(substantially)= ៤<br>ភាគច្រើន (mostly)=៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) =១ |
| Total Score | 100 | 71 | 73 | 69 | 74 | 76 | 70 | 78 | 71 | 72.8 | |

# គណៈកម្មការវាយតម្លៃ "សំណើពិពិធកម្មនិងធុរកិច្ចរបស់ សហគមន៍កសិកម្មស្ត្រីតេនៈ"

| ល.រ | ចំណុចត្រូវវាយតម្លៃ | ពិន្ទុអតិបរមា | ពិន្ទុផ្តល់ដោយសមាជិក | | | | | | | | | សេចក្តីពន្យល់ពីការដាក់ពិន្ទុ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | EC1 | EC2 | EC3 | EC4 | EC5 | EC6 | EC7 | EC8 | Average Score | |
| ១. ភាពពាក់ព័ន្ធនៃDPI ជាមួយក្របខ័ណ្ឌគម្រោង | | | | | | | | | | | | |
| | ១.១. សនិទានភាព (ហេតុផល) និងគោលដៅ DPI គឺរៀបចំសរសេរបានល្អ<br>The rationale and objectives of the proposed DPI are well formulated | 5 | 3 | 4 | 4 | 4 | 4 | 3 | 4 | 4 | 3.8 | គួរឱ្យចាប់អារម្មណ៍ខ្លាំង (impressive) = ៥;<br>ល្អប្រសើរ (substantially)= ៤<br>ល្អ (good) = ៣;<br>ខ្លះៗ (Some) = ២,<br>ខ្សោយ (poor) = ១ |
| | ១.២. ភាពពាក់ព័ន្ធរបស់DPI នេះ នឹងជួយឱ្យសម្រេចគោលដៅគម្រោង CASDP<br>The relevance of the proposed DPI to reach the objective of the CASDP project | 5 | 3 | 3 | 4 | 4 | 4 | 4 | 4 | 4 | 3.8 | គួរឱ្យចាប់អារម្មណ៍ខ្លាំង (impressive) = ៥;<br>ល្អប្រសើរ (substantially) = ៤;<br>ល្អ (good) = ៣;<br>ខ្លះៗ (some) = ២,<br>ខ្សោយ (poor) = ១ |
| ២. បទពិសោធន៍របស់គូរអង្គពាក់ព័ន្ធ | | | | | | | | | | | | |
| | ២.១. ចំនួនឆ្នាំគិតជាមធ្យមនៃការប្រកបអាជីវកម្មរបស់ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូច និងមធ្យម ដែលបានចុះបញ្ជី<br>Average year of legal constitution of POs and SMAs | 5 | 4 | 4 | 4 | 4 | 4 | 3 | 4 | 3 | 3.8 | លើសពី ៣ ឆ្នាំ = ៥;<br>ចន្លោះពី ២ ទៅ ៣ ឆ្នាំ = ៤;<br>ចន្លោះពី ១ ទៅ ២ ឆ្នាំ = ៣;<br>ចន្លោះពី ០,៥ ទៅ ១ ឆ្នាំ =២;<br>តិចជាង ០,៥ ឆ្នាំ = ១ |
| | ២.២. បទពិសោធន៍របស់ក្រុមផលិត ក្នុងការលក់ផលិតរបស់ខ្លួនរួមគ្នាជាក្រុម<br>Experience of PO to market their products together as a group | 5 | 3 | 3 | 4 | 4 | 3 | 3 | 4 | 3 | 3.4 | គួរឱ្យចាប់អារម្មណ៍ខ្លាំង = ៥;<br>ល្អប្រសើរ = ៤;<br>ល្អ = ៣;<br>ខ្លះៗ = ២,<br>ខ្សោយ = ១ |
| | ២.៣. BPI នីមួយៗ របស់ DPI មានភ្ជាប់មកជាមួយនូវ លិខិតបញ្ជាក់បំណងក្នុងការទិញទំនិញពីដៃគូអ្នកបញ្ជា ទិញ<br>Each BPI of the DPI is supported by a letter of intent of purchase by a potential buyer. | 5 | 3 | 4 | 3 | 4 | 3 | 3 | 4 | 4 | 3.5 | DPI មានលិខិតបញ្ជាក់បំណង ១០០% = ៥;<br>DPI មានលិខិតបញ្ជាក់បំណងលើសពី៥០% = ៤<br>DPI មានលិខិតបញ្ជាក់បំណង ៥០%=៣<br>DPI មានលិខិតបញ្ជាក់បំណងតិចជាង ៥០%=២<br>DPI ពុំមានលិខិតបញ្ជាក់បំណង ០%=១ |
| ៣. ការរៀបចំDPI/ BPI | | | | | | | | | | | | |
| | ៣.១. ការជ្រើសរើសការ វិនិយោគដែលមានផលិតភាពនៅក្នុង BPI របស់ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូច និងមធ្យមគឺត្រឹមត្រូវ និងសមស្រប ដែលនឹងអាចសម្រេច បានទៅតាមគោលដៅ របស់ DPI និង BPI ហើយនិងគោលដៅអភិវឌ្ឍន៍របស់គម្រោង<br>(Productive investment in BPI for POs and SMAs are well chosen to achieve the objective of the DPI and BPI and the development objective of the Project.) | 10 | 8 | 6 | 8 | 8 | 8 | 8 | 6 | 8 | 7.5 | ទាំងស្រុង (Totally) = ១០;<br>បង្គួរ (substantially) = ៨;<br>ភាគច្រើន (mostly) = ៦;<br>ល្មមគ្រប់គ្រាន់ (just enough) = ៤;<br>មិនគ្រប់គ្រាន់ (not enough) = ២ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ៣.២. ផែនការ BPI នៅក្នុង DPI គឺមានដាក់បញ្ចូលនូវ ដំណើរការ ក្នុងកម្រិតកសិដ្ឋាន, ប្រមូលផ្តុំ, កែច្នៃ និងទីផ្សារ ដែលមានលក្ខណៈពាណិជ្ជកម្ម ដោយប្រើប្រាស់ បច្ចេកវិទ្យា ដែលមានលក្ខណៈនវានុវត្តន៍<br>BPI in DPI include/s innovative technological and commercial processes at farm, aggregation, processing and marketing level. | 5 | 3 | 4 | 3 | 4 | 4 | 3 | 4 | 4 | 3.6 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially) = ៤;<br>ភាគច្រើន (mostly) = ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| ៣.៣. ផែនការ BPI នៅក្នុង DPI មានការដាក់បញ្ចូលនូវការបន្ថែមតម្លៃដល់ផលិតផល កសិកម្មបឋម តាមរយៈការធ្វើ បម្លាស់ប្រែ ឬការកែឆ្នៃ ការជ្រើសរើស និងការធ្វើ ចំណាត់ថ្នាក់ផលិតផល តាមរយៈការវេចខ្ចប់ និងដាក់ស្លាក សម្គាល់ ជាដើម<br>BPI in DPI propose/s adding value to primary production through transformation/processing, or through product sorting and selection by physical traits and/or packing, packaging and/or labelling. | 5 | 4 | 3 | 3 | 4 | 4 | 3 | 4 | 3 | 3.5 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially)= ៤;<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough)= ២;<br>មិនគ្រប់គ្រាន់ (not enough)= ១ |
| ៣.៤. ផែនការវិនិយោគលើ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ត្រូវបានជ្រើសរើសយ៉ាងត្រឹមត្រូវ ដើម្បីគាំទ្រដល់ការ សម្រេចគោលបំណង DPI និងគោលបំណងអភិវឌ្ឍន៍របស់គម្រោង ហើយថវិកា ដែលស្នើឡើងមាន លក្ខណៈ សមស្រប<br>Supporting public investments are well chosen to support achieving the objective of the DPI and the development objective of the Project, and are within acceptable budget | 5 | 3 | 3 | 3 | 4 | 4 | 4 | 3 | 3 | 3.4 | **ក. ការវាយតម្លៃដាក់ពិន្ទុប្រសិនបើសហគមន៍បានស្នើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ**<br>ទាំងស្រុង (Totally)= ៥<br>បង្គួរ (substantially)= ៤;<br>ភាគច្រើន (mostly)= ៣;<br>**ខ. ការវាយតម្លៃដាក់ពន្ទុប្រសិនបើសហគមន៍បានស្នើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ**<br>ពិន្ទុផ្តល់ឱ្យ÷ ៣ |
| ៣.៥. BPI នៅក្នុង DPI មាន អំណះអំណាងច្បាស់លាស់ដែលបញ្ជាក់ថា តម្រូវការទីផ្សារសម្រាប់ផលិតផល/ សេវាកម្ម ដែលបានស្នើឡើង កំពុងមានការកើនឡើង<br>The BPI under the DPI is/are supported by evidence that the targeted market for proposed products/services is growing. | 5 | 4 | 4 | 4 | 3 | 4 | 4 | 4 | 4 | 3.9 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially)= ៤;<br>ភាគច្រើន (mostly) = ៣;<br>ល្មមគ្រប់គ្រាន់ (just enough)= ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| ៣.៦. BPI នៅក្នុង DPI បានដាក់បញ្ចូលនូវការអនុវត្តកសិកម្មល្អ (GAP) និងការអនុវត្តល្អក្នុងកម្រិតរោងចក្រ/ សហគ្រាស/ សិប្បកម្ម/ កន្លែងកែច្នៃផលិតផលកសិកម្ម (GMP)<br>BPI under DPI explicitly incorporate good agricultural practices and good manufacturing practices | 5 | 3 | 3 | 3 | 3 | 5 | 3 | 3 | 3 | 3.3 | ទាំងពីរ (Both) = ៥;<br>មួយក្នុងចំណោមទាំងពីរ (One of them) = ៣;<br>មិនមានណាមួយ (none)= ១ |
| **៤. ឧបសគ្គ និងហានិភ័យ ដែលនឹងត្រូវធ្វើការឆ្លើយតប** | | | | | | | | | | | |
| តើមានការរៀបរាប់អំពីហានិភ័យ ដែលសហគមន៍/ ក្រុមផលិត/ កសិធុរកិច្ចខ្នាតតូច និងមធ្យម កំពុងជួបប្រទះនាពេលបច្ចុប្បន្ន និងវិធានការដើម្បីកាត់បន្ថយហានិភ័យទាំងនោះដែរឬទេ?<br>Are current risks and mitigation measures well formulated? | 5 | 3 | 4 | 3 | 3 | 4 | 3 | 4 | 2 | 3.3 | ទាំងស្រុង (Totally) = ៥;<br>បង្គួរ (substantially) = ៤;<br>ភាគច្រើន (mostly) = ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| **៥. ការវិភាគហិរញ្ញវត្ថុ** | | | | | | | | | | |
| លទ្ធភាពទទួលបានផលចំណេញជាមធ្យមសម្រាប់ការវិនិយោគដែលបានស្នើឡើង ដោយ PO និង SMA ដែលត្រូវបានបង្ហាញជាអត្រាផលចំណេញសុទ្ធ ដែលស្មើនឹង ផលចំណេញសុទ្ធ ធៀបនឹងចំណូលពីការលក់ (Net Margin = Net Profit/ Revenues) Average financial viability for proposed investment of POs and SMAs expressed in Net Margin (= Net Profit / Revenues) | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5.0 | ជាង ១០% (More than 10%) = ៥<br>រហូតដល់ ១០% (Up to 10%) = ៣<br>រហូតដល់ ៥% (Up to 5%) = ១ |
| **៦. ផលជះផ្នែកបរិស្ថាន** | | | | | | | | | | |
| តើគម្រោងនេះផ្តល់ផលជះអ្វីខ្លះដល់បរិស្ថាន?<br>What is the impact of the project on the environment? | 5 | 4 | 4 | 3 | 4 | 3 | 3 | 4 | 4 | 3.6 | វិជ្ជមានខ្ពស់ (Very Positive) = ៥;<br>វិជ្ជមាន (Positive) = ៤;<br>វិជ្ជមានដែរ (rather positive) = ៣;<br>ធម្មតា (Neutral) = ២;<br>អវិជ្ជមាន(Negative)=១ |
| **៧. ផលជះផ្នែកសង្គមរបស់គម្រោង** | | | | | | | | | | |
| ៧.១. តើបានបញ្ជាក់ច្បាស់លាស់ពីផលជះអវិជ្ជមានផ្នែកសង្គម ចេញពីគម្រោងដែរឬទេ?<br>Are adverse social impacts identified | 5 | 3 | 3 | 3 | 3 | 3 | 3 | 5 | 3 | 3.3 | ទាំងស្រុង (Totally) =៥;<br>ភាគច្រើន (mostly)= ៣;<br>មិនគ្រប់គ្រាន់ (not sufficiently) = ១ |
| ៧.២. តើ DPI នេះបានបង្កើតការងារថ្មីៗដែរឬទេ? (ការងារអចិន្ត្រៃយ៍ និងការងារតាមរដូវកាល)<br>Does the DPI create new jobs (permanent and seasonal) | 5 | 4 | 4 | 3 | 4 | 4 | 4 | 3 | 3 | 3.6 | ជាង ២០ នាក់ = ៥;<br>ចន្លោះ ១០ និង ២០ នាក់ = ៤;<br>ចន្លោះ ៥ និង ១០ នាក់ = ៣;<br>ចន្លោះ ១ និង ៥ នាក់ = ២;<br>មិនមាននរណាម្នាក់ឡើយ (none) = ១ |
| ៧.៣. តើ DPI នេះ មានផែនការជាក់លាក់ដើម្បីធានាថាស្ត្រី យុវជន និងក្រុមងាយរងគ្រោះឯទៀតនឹងទទួលបានផលប្រយោជន៍ពីគម្រោង ដែរឬទេ?<br>Does the DPI has concrete plans how to make sure that women and youth and other vulnerable groups will benefit from the Project? | 5 | 4 | 4 | 3 | 3 | 4 | 4 | 4 | 3 | 3.6 | ទាំងស្រុង (Totally)= ៥;<br>បង្គួរ(substantially)= ៤<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough)= ២;<br>មិនគ្រប់គ្រាន់ (not enough)=១ |
| ៧.៤. BPI និងផែនការច្រវាក់តម្លៃ ដែលបានជ្រើសរើស មាននិយិទ្ធភាពទៅនឹងអាហារូបត្ថម្ភ (Nutrition Sensitive) ឬទេ ហើយផែនការទាំងនោះ អាចត្រូវបានកំណត់ថាជាផែនការដែលបានរួមចំណែកដល់ការកាត់បន្ថយបញ្ហានៃកង្វះអាហារូបត្ថម្ភ ក្នុងចំណោមប្រជាជនកម្ពុជាដែរឬទេ? Are the BPI and selected value chains nutrition-sensitive and can they be defined as those that can contribute to reducing undernutrition in the Cambodian population? | 5 | 3 | 3 | 3 | 2 | 3 | 3 | 3 | 3 | 2.9 | ទាំងស្រុង (Totally)= ៥;<br>បង្គួរ(substantially)= ៤<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| ៧.៥. តើ BPI និងផែនការខ្សែច្រវាក់តម្លៃផ្តោតទៅលើការនាំចេញ ហើយផែនការទាំងនោះអាចត្រូវបានកំណត់ថាជាផែនការដែលអាចរួមចំណែកដល់ការជំរុញការនាំចេញផលិតផលកសិកម្មកម្ពុជា ដែរឬទេ?<br>Are the BPI and selected value chains export-oriented and can they be defined as those that can contribute to promoting Cambodia"s exports of agricultural products? | 5 | 3 | 4 | 3 | 4 | 3 | 4 | 4 | 3 | 3.5 | ទាំងស្រុង (Totally)= ៥;<br>បង្គួរ(substantially)= ៤<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| **Total Score** | 100 | 70 | 72 | 69 | 74 | 76 | 70 | 76 | 69 | 72.0 | |

## ៦. សេចក្តីសន្និដ្ឋានរបស់គណៈកម្មការវាយតម្លៃ

យោងតាមលទ្ធផលនៃការវាយតម្លៃ និងការដាក់ពិន្ទុលើសំណើពិពិធកម្មនិងធុរកិច្ចរបស់ "សហគមន៍កសិកម្មសាមគ្គីភ្នំពេជ្របុរី" ទទួលបានពិន្ទុចំនួន ៧២,៨០ និង "សហគមន៍កសិកម្មស្ត្រីរតនៈ" ទទួលបានពិន្ទុចំនួន ៧២,០០ គឺមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបន្តរៀបចំផែនការពិពិធកម្មនិងធុរកិច្ចលម្អិត។ អាស្រ័យហេតុនេះ សមាជិកគណៈកម្មការ EC ទាំងអស់បានសម្រេច និងឯកភាពបញ្ជូនលទ្ធផលនេះ ជូនទៅគណៈកម្មការប្រឹក្សាយោបល់ និងអនុម័ត (AEC) ធ្វើការពិនិត្យ និងសម្រេចជាផ្លូវការលើលទ្ធផលនៃវាយតម្លៃនេះ ដើម្បីផ្តល់លទ្ធភាពឱ្យសហគមន៍កសិកម្ម អាចរៀបចំផែនការពិពិធកម្មនិងធុរកិច្ចបន្ត។

ទន្ទឹមនេះ គណៈកម្មការស្នើឱ្យសហគមន៍ទាំងពីរត្រូវរៀបរាប់ឱ្យច្បាស់លាស់នូវព័ត៌មានមួយចំនួននៅក្នុងផែនការពិពិធ-កម្មនិងធុរកិច្ច ដូចខាងក្រោម÷

- លិខិតបញ្ជាក់បំណង ឬកិច្ចសន្យាផលិតកម្មប្រចាំឆ្នាំ រវាងសហគមន៍កសិកម្ម និងដៃគូបញ្ជាទិញ (ស៊ីអេស៊ីស៊ី និងហាងឲ្យហារវេស អេហ្គ្រីខលឈ័រ ខូអិលធីឌី) ត្រូវមានសុពលភាពឱ្យបានត្រឹមត្រូវច្បាស់លាស់ និងពិតប្រាកដ (មិនមែនកិច្ចសន្យាឆ្នាំចាស់)។
- ការយកសំណាកសម្រាប់ការវិភាគហិរញ្ញវត្ថុ (កម្រិតក្រុមផលិត) ត្រូវជ្រើសរើសភាគរយនៃសមាជិកចូលរួម រួមមាន÷ យកពីខ្នាតតូច មធ្យម និងខ្នាតធំ។ អត្រាប្រាក់ចំណេញសុទ្ធនៃសកម្មភាពទាំងកម្រិតសហគមន៍ និងក្រុមផលិត មិនគួរមានក្រោម ១០% ទេ។
- បង្ហាញប្រាក់ចំណូល ចំណាយ ចំណេញ និងអត្រាផលចំណេញសុទ្ធសម្រាប់កម្រិតក្រុមផលិត ដូចបានធ្វើកម្រិតសហគមន៍ដែរ។
- ចំណាយប្រត្តិបត្តិការ (កម្រិតសហគមន៍) មានដូចជា ទឹកពិសារ កាតទូរស័ព្ទ អាហារ សាំងម៉ូតូ និងចំណាយមិនទាក់ទងផ្ទាល់នឹងផលិតកម្ម ឬធុរកិច្ចរបស់សហគមន៍ (ហ្វីត ក្រដាសរាម ទឹកព្រីនធ័រ) មិនគួរដាក់បញ្ចូលទេ។ លម្អិតមុខចំណាយប្រត្តិបត្តិការ (កម្រិតក្រុមផលិត)។
- សម្រាប់ដំឡូងមីស្ងួត ក្រុមហ៊ុនហាងឲ្យហារវេស បន្ថែមតម្លៃ ៣-៥ ដុល្លារ/តោន (មិនមែន ២០% ក្នុង ១ គក្រទេ) ដូច្នេះ ពិនិត្យកែសម្រួលលទ្ធផលនៃការវិភាគឡើងវិញ។
- បរិយាយពីការវិនិយោគដែលមានចំណាយធំៗ÷ សាងសង់ឃ្លាំង ទិញរថយន្ត (កម្រិតសហគមន៍) និងការទិញត្រាក់ទ័រ (កម្រិតក្រុមផលិត) តើការប្រើប្រាស់ ឃ្លាំង រថយន្ត និងត្រាក់ទ័រ បានរួមចំណែកកម្រិតណាដល់ (i) ការជួយបង្កើនផលិតភាពធុរកិច្ចស្មើឡើង (ទីផ្សារដំឡូងមីនៅកម្រិតសហគមន៍) និង (ii) ការជួយបង្កើនផលិតភាពដំឡូងមី (គ្រួសារកសិករដែលចូលរួម)។
- ការចំណាយលើការកាត់វិលស់ ការសាងសង់ឃ្លាំង ឡានដឹកដំឡូង ។ល។ គួរដាក់រួមគ្នា ១ កញ្ចប់ ក្រោមចំណងជើង "ការកាត់វិលស់លើការសាងសង់ឃ្លាំង ឡានដឹកដំឡូង"។

ជាកិច្ចបញ្ចប់ **លោក ឡៅ ប៉ូលីវេត** ប្រធានគណៈកម្មការ EC បានធ្វើការថ្លែងអំណរគុណដល់សមាជិកអង្គប្រជុំទាំងអស់ ដែលបានចំណាយពេលវេលាចូលរួមកិច្ចប្រជុំ និងស្នើសុំសមាជិកគណៈកម្មការ EC ចូលរួមកិច្ចប្រជុំបន្ទាប់ **នៅថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ ២០២១** វេលាម៉ោង ០៩ :០០ នាទីព្រឹក ក្នុងគោលបំណងពិនិត្យ, វាយតម្លៃ និងដាក់ពិន្ទុលើសំណើពិពិធកម្មនិងការធុរកិច្ច របស់ “**សហគមន៍កសិកម្មតស៊ូសែនជ័យ**” និង “**សហគមន៍កសិកម្មក្របៅព្រហ្មទេព**”។ **លោកប្រធាន** បានប្រកាសបិទអង្គប្រជុំ នៅថ្ងៃដដែល វេលាម៉ោង ១៥ : ០០ នាទី។

ថ្ងៃចន្ទ ២ កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០២១

**លេខាធិការ**

**នៃគណៈកម្មការវាយតម្លៃ**

**ឃាន កុសល**

ថ្ងៃចន្ទ ២ កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០២១

**យោបល់**

បានឃើញ និងឯកភាព

**ប្រធានគណៈកម្មការវាយតម្លៃ**

**ឡៅ ប៉ូលីទេត**